ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៨/២១ - វ៉ៃ ហ៊្វល ហ្កាមេន (ខេមបូឌា) អិលធីឌី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១
យោបល់ជំទាស់ទៅនឹងសេចក្តីបង្គាប់ ៖ ដោយអាជ្ញាកណ្តាល អាន វីរៈ

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន វ៉ៃ ហ៊្វល ហ្កាមេន (ខេមបូឌា) អិលធីឌី**
អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៤៣ ៩២ ២៣ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក តាំង ម៉េង មេធាវី
២- លោក ម៉ី សុខុន រដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន វ៉ៃ ហ៊្វល ហ្កាមេន (ខេមបូឌា) អិលធីឌី**
អាសយដ្ឋាន ៖ ភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៨៨ ០០ ៣៩ / ០៩៦ ២២ ១២ ៤១៣ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោកស្រី យ៉ាង សុភណ្ឌ័ ប្រធានសហព័ន្ធសហជីពកម្ពុជា
២- កញ្ញា ផល ចាន់ថា មន្ត្រីចងក្រងសហព័ន្ធសហជីពកម្ពុជា
៣- លោក ព្រីង ប៊ុន ប្រធានសហជីព (មូលដ្ឋាន)
៤- លោក យន ប៊ុន អនុប្រធានសហជីព (មូលដ្ឋាន)

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ៖ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

៥- លោក ចែម សុភ័ក្ត្ត    លេខាសហជីព (មូលដ្ឋាន)

៦- លោក សំ រិន្ទា    ហេរញ្ញិកសហជីព (មូលដ្ឋាន)

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើរោងចក្រ រាល់ពេលបញ្ឈប់កម្មករនិយោជិតពីការងារ ទូទាត់អតីតភាពការងារស្របតាម ច្បាប់ស្តីពីការងារ។ ភាគីនិយោជកសុំអនុវត្តតាមច្បាប់។

២- ស្នើរោងចក្រ រាល់ការតំឡើងប្រាក់ឈ្នួលពីរដ្ឋាភិបាល ត្រូវបូកបន្ថែមពីលើប្រាក់ខែគោលរបស់ កម្មករដែលមានស្រាប់។ ភាគីនិយោជកសុំអនុវត្តតាមច្បាប់។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំង សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិ ទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាម ជំពូកទី១២ ផ្នែកទី២(ក)នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នា ឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ី ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី លេខ ០៩០/២១ ក.ប/កណ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃសុក្រ ២រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ០០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួល លិខិតស្នើសុំឱ្យជួយដោះស្រាយវិវាទការងាររបស់ប្រតិភូចរចា នៃក្រុមហ៊ុន វ៉ី ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី។ បន្ទាប់ពីបានទទួលបានលិខិតស្នើសុំនេះរួចមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត កណ្តាល បានអញ្ជើញគូភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម និងបានធ្វើការផ្សះផ្សា នៅថ្ងៃទី១ ខែមីនា ឆ្នាំ ២០២១ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១១ចំណុច លើការទាមទារចំនួន ១៣ចំណុច។ ចំណុចមិន សះជាចំនួន ២ចំណុច ដែលនៅសល់ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ

THE ARBITRATION COUNCIL

២០២១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន វ៉ៃ ហ្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី លេខ ០៩០/២១ ក.ប/កណ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២១។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជា នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ២ និង០០ នាទីរសៀល។ ទន្ទឹមនឹងនោះដែរ ដោយសារតែការរីករាលដាលឆ្លងចូលសហគមន៍ នៃវីរុសកូវីដ១៩ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០២១ ភាគីទាំងពីរបានព្រមព្រៀងគ្នាស្នើសុំពន្យារនីតិវិធីអាជ្ញាកណ្តាល តាមរយៈលិខិតចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២១។ បន្ទាប់ពីបានទទួល និងពិនិត្យលើលិខិតស្នើសុំពន្យារនីតិវិធីអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលបានឯកភាពតាមការស្នើសុំនេះផងដែរ។ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញា-កណ្តាលបានទទួលលិខិត ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ របស់ភាគី ស្តីពីការស្នើសុំបន្តនីតិវិធីក្រុមប្រឹក្សាអាជ្ញា-កណ្តាលឡើងវិញ។ ក្រុមអាជ្ញាកណ្តាលបានទទួល និងពិនិត្យលើលិខិតស្នើសុំនេះ និងបានកំណត់ថ្ងៃសវនាការនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ៩ និង ០០ នាទីព្រឹក នៅការិយាល័យក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ២ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយភាគីកម្មករនិយោជិតយល់ព្រមដកចំណុចវិវាទទី២ ចេញពីការទាមទារនៃសំណុំរឿងនេះ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទដែលនៅសល់ គឺចំណុចវិវាទទី១។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយការរកឃើញនៃអង្គហេតុ និងផ្អែកលើភស្តុតាង ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតចុះថ្ងៃចន្ទ ៨កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២១ របស់តំណាងភាគីនិយោជកនៃក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី និង តំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំពន្យារនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលសំណុំរឿងលេខ ០០៨/២១-វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

២- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃចន្ទ ១រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ របស់ក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូន លោកមេធាវី តាំង ម៉េង និង លោក ម៉ៃ សុខុន។

៣- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ របស់អាណត្តិទាយក ក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី សូមប្រគល់សិទ្ធិជូន លោកមេធាវី តាំង ម៉េង ជាមេធាវីតំណាងដោយអាណត្តិឱ្យអាណត្តិទាយកក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី ក្នុងសំណុំរឿងលេខ ០០៨/២១ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី លេខ MOC 89603732 ពណ.ចបព ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១១។

៥- លក្ខន្តិកៈក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី បានតំកល់ទុកលេខ ៤៤២៩/១៧គ.រ.ក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧។

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី ចុះទិដ្ឋាកាលេខ ៧៤៨/២០ ក.ប.វ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០។

៧- លិខិតលេខ ០៧០ ក.ប/អ.ក/អធក ចុះថ្ងៃសុក្រ ១៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ របស់នាយកដ្ឋានអធិការកិច្ចការងារ ជម្រាបជូន លោកឧកញ៉ា ប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ស្តីពីរបៀបគិតអតីតភាពការងារ ដើម្បីកំណត់រយៈពេលជូនដំណឹងមុន ដែលនិយោជកត្រូវអនុវត្តពេលបញ្ចប់កិច្ចសន្យាការងារ ក្នុងករណីដែលកិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) ក្លាយទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC)។

៨- សេចក្តីណែនាំលេខ ០៥៨/១៩ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃចន្ទ ៨កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារថ្មី ក្នុងឆ្នាំនីមួយៗ ចាប់ពីឆ្នាំ២០១៩។

៩- ប្រកាសលេខ ៣០៣/២០ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃព្រហស្បតិ៍ ៨រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០២១។

១០- សេចក្តីជូនដំណឹងលេខ ០២៣/១៩ ប.ក/ស.ជ.ណ.ខ.ល ចុះថ្ងៃចន្ទ ៧កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបើកផ្តល់ប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ និងការទូទាត់ប្រាក់បំណាច់អតីតភាពការងារថ្មីចាប់ពីឆ្នាំ២០១៩ តទៅ សម្រាប់សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង។

THE ARBITRATION COUNCIL

១១- លិខិតចុះថ្ងៃអង្គារ ១៤កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០២១ របស់ក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី គោរពជូន លេខាធិការដ្ឋានក្រុម-ប្រឹក្សាអាជ្ញាកណ្តាល ស្តីពីក្រុមហ៊ុនមិនអាចចូលរួមសវនាការក្នុងសំណុំរឿងលេខ ០០៨/២១។

១២- លិខិតចុះថ្ងៃចន្ទ ១៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០២១ របស់ក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី គោរពជូន លោកប្រធាននាយក-ដ្ឋានអធិការកិច្ចការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីសំណើសុំបិតរោងចក្រ វ៉ៃហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី ដែលមានទីតាំងនៅក្នុងភូមិពងទឹក ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល។

១៣- បញ្ជីបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត។

១៤- លិខិតលេខ ១៧២ ក.ប/អ.ក/អធក ចុះថ្ងៃសុក្រ ២រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ របស់នាយកដ្ឋានអធិការកិច្ចការងារ ជម្រាបជូនលោកនាយកក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី ស្តីពីការជូនដំណឹងអំពីការបិទទ្វារលែងដំណើរការរបស់ក្រុមហ៊ុន។

១៥- លិខិតចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២១ របស់ក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសុំប្តឹងជំទាស់នឹងឯកសាររបស់សហជីពកម្ពុជា ដែលដាក់ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចុះថ្ងៃចន្ទ ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៥ ខែមេសា ឆ្នាំ២០២១ របស់តំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំពន្យាពេលសវនាការសំណុំរឿងលេខ ០០៨/២១- ក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី ។

២- លិខិតចុះថ្ងៃចន្ទ ៨កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២១ របស់តំណាងភាគីនិយោជកនៃក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី និងតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំព្យួរនីតិវិធីក្រុមប្រឹក្សា-អាជ្ញាកណ្តាលសំណុំរឿងលេខ ០០៨/២១-វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

៣- លិខិតចុះថ្ងៃចន្ទ ៦កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០២១ របស់តំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីស្នើសុំបើកសវនាការនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលសំណុំរឿងលេខ ០០៨/២១- រោងចក្រកាត់ដេរ វ៉ៃ ហ៊្វុល-ហ្គាមេន (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

THE ARBITRATION COUNCIL

៤- លិខិតចុះថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ របស់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម គោរពជូន ក្រុមប្រឹក្សា-អាជ្ញាកណ្តាល ស្តីពីសារណាការពារក្តីក្នុងសំណុំរឿងលេខ ០០៨/២១។

៥- បញ្ជីឈ្មោះកម្មករកម្មការិនី នៅក្រុមហ៊ុន វ៉ៃ ហ៊្វុល ដែលក្រុមហ៊ុនបញ្ឈប់ពីខែ១២ ឆ្នាំ២០២០ រហូតមកដល់បច្ចុប្បន្ននេះ (ទូទាត់មិនត្រឹមត្រូវ)។

៦- តារាងពង្រាងគិតប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗតាមច្បាប់ (ក្រុមហ៊ុន វ៉ៃ ហ៊្វុល)។

៧- ចុងសន្លឹកបើកប្រាក់ឈ្នួលដែលកម្មករនិយោជិតទទួលបាន (ចុងក្រោយ និងបើកប្រាក់ឈ្នួល)។

៨- លិខិតជំទាស់ ចុះថ្ងៃចន្ទ ១២រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១ របស់ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជំទាស់ទៅនឹងឯកសារក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី លេខ ០៩០/២១ ក.ប/កណ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២១។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន វ៉ៃ ហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី លេខ ០០២/២១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៤៧ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៤៨ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៤៩ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១១រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ ០៥០ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១១រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១។

៥- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៥២ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១។

៦- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ ០៥៣ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១៣កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១។

THE ARBITRATION COUNCIL

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ៖**

- ក្រុមហ៊ុននេះ មានសកម្មភាពចម្បងផ្នែកកាត់ដេរសំលៀកបំពាក់នាំចេញ និងមានជួលកម្មករនិយោជិតសរុបចំនួន ៦២០នាក់ ដែលអ្នកពាក់ព័ន្ធនឹងចំណុចវិវាទនេះបានផ្ដិតមេដៃទាមទារចំនួន ៣៣២នាក់។ *(យោងតាមរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វ៉ៃ ហ្វុល ហ្គាមេន (ខេមបូឌា) លីមីធីត)*
- មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកណ្ដាល បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមលេខ ០០២/២១ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ដែលមានកម្មករនិយោជិតចំនួន ៤នាក់ មានដូចជា ១. ចែម សុភ័ក្ត, ២. យន ប៊ុន, ៣.គ្រឹង ថុន, និង ៤. សំ រិន្ដា ដែលអ្នកទាំង៤ មានវត្តមាននៅថ្ងៃសវនាការដែរ ។

**ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតស្នើសុំឱ្យរោងចក្ររាល់ពេលបញ្ឈប់កម្មករនិយោជិតពីការងារ ទូទាត់អតីតភាពការងារតាមច្បាប់ស្ដីពីការងារ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកគិតអតីតភាពការងាររបស់កម្មករនិយោជិតម្នាក់ៗ ដោយគិតចាប់ ពីកិច្ចសន្យាការងារដំបូង រហូតដល់ថ្ងៃបញ្ឈប់ពីការងារ សម្រាប់ទូទាត់ប្រាក់បំណាច់ជួសការជូនដំណឹងមុន ប្រាក់បំណាច់អតីតភាពការងារ និងសោហ៊ុយដំងឺចិត្តជូនកម្មករនិយោជិត។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - ០ និយោជកបានបញ្ឈប់កម្មករនិយោជិតពីការងារ ដោយទូទាត់ប្រាក់បំណាច់ផ្ដាច់កិច្ចសន្យា រួមមានប្រាក់ឈ្នួលចុងក្រោយ ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ ប្រាក់បំណាច់អតីតភាពការងារ ប្រាក់បំណាច់ជួសការជូនដំណឹងមុន និងប្រាក់កែតម្រូវ។
    - ០ និយោជកបានទូទាត់ប្រាក់បំណាច់ជួសការជូនដំណឹងមុនចំនួន ១៥ថ្ងៃ ប្រាក់បំណាច់អតីតភាពការងារចំនួន ១៨ថ្ងៃ កន្លះ និងប្រាក់កែតម្រូវជូនកម្មករនិយោជិត។
    - ០ នៅចុងឆ្នាំ២០១៩ និយោជកបានផ្លាស់ប្ដូរកិច្ចសន្យាការងាររបស់កម្មករនិយោជិតដែលមានថិរវេលាកំណត់ ទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់វិញ និងបានទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារដែលមានថិរវេលាកំណត់ចំនួន ៥ភាគរយ ជូនកម្មករនិយោជិតរួចហើយ មុនពេលផ្លាស់ប្ដូរនេះ។
    - ០ ភាគីយល់ព្រមឱ្យក្រុមអាជ្ញាកណ្ដាលដោះស្រាយតែចំណុចវិវាទដែលមាននៅក្នុងសំណុំរឿងនេះ តែប៉ុណ្ណោះ។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
    - ០ កម្មករនិយោជិតដែលទាមទារនៅក្នុងចំណុចនេះមានចំនួន ៣៣២នាក់ ដូចនឹងចំនួនដែលមាននៅក្នុងរបាយការណ៍មិនសះជារបស់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល បញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

- ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅតែមានយុត្តាធិការដោះស្រាយសំណុំរឿងនេះដដែល ព្រោះសំណុំរឿងនេះបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលតាំងពីពេលនិយោជកមិនទាន់បិទរោងចក្រ តែដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ការបិទខ្ទប់រាជធានីភ្នំពេញ និងការហាមឃាត់មិនឱ្យធ្វើដំណើរឆ្លងកាត់ខេត្តទូទាំងប្រទេសដោយរាជរដ្ឋាភិបាល ទើបបណ្តាលឱ្យសំណុំរឿងនេះពន្យារនីតិវិធីសវនាការ។
- កម្មករនិយោជិតមួយចំនួន ដូចជាកម្មករនិយោជិតឈ្មោះ សំ វិត ត្រូវបាននិយោជកបញ្ឈប់មុនថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ និងកម្មករនិយោជិតផ្សេងៗទៀត ត្រូវបាននិយោជកបញ្ឈប់ជាបន្តបន្ទាប់ក្រោយថ្ងៃទី១៥ មករា ឆ្នាំ២០២១។
- ដោយសារកត្តាជីវភាព និងបញ្ហាជំងឺកូវីដ-១៩ កម្មករនិយោជិតព្រមទទួលយកការទូទាត់ប្រាក់បំណាច់ចំនួន ៥ចំណុច ពីនិយោជក បើទោះជានិយោជកទូទាត់មិនត្រូវតាមច្បាប់។ តែក្រោយមកពួកគាត់ដាក់ពាក្យប្តឹងដើម្បីទាមទារឱ្យនិយោជកគិតប្រាក់បំណាច់សារឡើងវិញ។ ជាក់ស្តែង កម្មករនិយោជិតឈ្មោះ សំ វិត បានបដិសេធទទួលយកការទូទាត់ប្រាក់បំណាច់ ៥ចំណុចនេះ បន្ទាប់ពីបានឃើញសន្លឹកបើកប្រាក់ទូទាត់ជូនគាត់មានការគណនាមិនត្រឹមត្រូវ។
- និយោជកមិនបានគិតអតីតភាពរបស់កម្មករនិយោជិតម្នាក់ៗ ដោយរាប់គិតចាប់ ពីកិច្ចសន្យាការងារដំបូង រហូតដល់ថ្ងៃនិយោជកបញ្ឈប់កម្មករនិយោជិតនោះទេ តែនិយោជកគិតអតីតភាពរបស់កម្មករនិយោជិតម្នាក់ៗ ដោយរាប់ចាប់ពីថ្ងៃដែលនិយោជកបានប្តូរកិច្ចសន្យាការងាររបស់កម្មករនិយោជិតពីកិច្ចសន្យាការងារដែលមានថិរវេលាកំណត់ មកជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់នៅចុងឆ្នាំ២០១៩។
- និយោជកទូទាត់ប្រាក់បំណាច់ជួសការជូនដំណឹងមុនតែចំនួន ១៥ថ្ងៃប៉ុណ្ណោះ ដែលការទូទាត់នេះ មិនត្រឹមត្រូវនោះទេ។ ដោយផ្អែកលើអតីតភាពរបស់កម្មករនិយោជិតម្នាក់ៗ ពួកគាត់ត្រូវទទួលបានចំនួនលើសពីនេះ។
- កម្មករនិយោជិតមិនដឹងថា និយោជកគិតប្រាក់កែតម្រូវជូនកម្មករនិយោជិតផ្អែកលើអ្វី ហើយមិនដឹងជាប្រាក់អ្វីនោះទេ តែនិយោជកអះអាងថា គឺជាប្រាក់សោហ៊ុយជំងឺចិត្ត។ ហេតុដូចនេះ កម្មករនិយោជិតទាមទារឱ្យនិយោជកគិតសោហ៊ុយជំងឺចិត្តតាមច្បាប់ ព្រោះនិយោជកមិនមានហេតុផលត្រឹមត្រូវក្នុងការបញ្ឈប់កម្មករនិយោជិត។
- និយោជកទូទាត់ប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិតតែចំនួន ១៤ថ្ងៃកន្លះ គឺមិនត្រឹមត្រូវនោះទេ។ កម្មករនិយោជិតត្រូវទទួលបានប្រាក់បំណាច់អតីតភាពការងារចំនួន ១៥ថ្ងៃ។
- ការដែលនិយោជកគិតអតីតភាពការងាររបស់កម្មករនិយោជិត ដោយយោងតាមលិខិតលេខ ០៧០ កប/អក/អធក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ របស់លោក អ៊ុក ចាន់ធូ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ គឺធ្វើឱ្យបាត់ប្រយោជន៍របស់កម្មករនិយោជិតតាមច្បាប់ស្តីពីការងារ ហើយលិខិតនេះគ្រាន់តែជាការឆ្លើយតបទៅនឹងសមាគមរោងចក្រកាត់ដេរដោយឡែកប៉ុណ្ណោះ។
- កម្មករនិយោជិតមិនដែលបានដឹងថា និយោជកបិទរោងចក្រនោះទេ ទើបតែបានដឹងនៅថ្ងៃសវនាការអាជ្ញាកណ្តាល ហើយនិយោជកក៏មិនមានលិខិតបញ្ជាក់ថារោងចក្រត្រូវបិទទ្វារនោះទេ។

- ភាគីនិយោជកបញ្ជាក់ថា៖
    - ០ សំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលមិនគួរបន្តនីតិវិធីសវនាការទៀតទេ ព្រោះនិយោជកបានបិទរោងចក្រ និងបានទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារ រួមមានប្រាក់ឈ្នួលចុងក្រោយ ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ ប្រាក់បំណាច់អតីតភាពការងារ ប្រាក់បំណាច់ជួសការជូនដំណឹងមុន និងប្រាក់កែតម្រូវ (ប្រាក់សោហ៊ុយជំងឺចិត្ត) ទៅតាមច្បាប់ ជូនកម្មករនិយោជិតរួចហើយ។ ម្យ៉ាងទៀត ការទាមទាររបស់កម្មករនិយោជិតអត់មានភាពច្បាស់លាស់។
    - ០ មើលលើតថភាពផ្លូវច្បាប់ កម្មករនិយោជិតដែលទាមទារ ពួកគាត់បានផ្តិតមេដៃទទួលយកសំណងរួចហើយ មិនគួរលើកយកមកទាមទារទៀតទេ ព្រោះវាជារឿងចាស់ ហើយក៏គ្មានការទាមទារពីកម្មករនិយោជិតទៀតដែរ។
    - ០ ក្នុងចំណោមកម្មករនិយោជិតជាង ៤០០នាក់ ដែលនិយោជកបានបញ្ឈប់ មានតែកម្មករនិយោជិត ២នាក់ប៉ុណ្ណោះ ដែលមិនទាន់ទទួលយកប្រាក់ទូទាត់បញ្ចប់កិច្ចសន្យាការងារចំនួន ៥ចំណុច ពីនិយោជក មានដូចជា ឈ្មោះ សំ រិត និង គិន សុខឃី ហើយដោយសារតែពួកគាត់មិនទាន់បានបើកប្រាក់ទូទាត់ ដូចនេះមិនដឹងថា និយោជកគណនាខុស ឬត្រូវនោះទេ។
    - ០ ចំពោះកម្មករនិយោជិតឈ្មោះ សំ រិត គឺនិយោជកបានទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យា ៥ ភាគរយ ជូនគាត់តាំងពីពេលគាត់ចូលធ្វើការ រហូតដល់ចុងឆ្នាំ២០១៩។
    - ០ និយោជកបានបញ្ជូនលិខិតជូនដំណឹងអំពីការបិទរោងចក្រទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាលរួចហើយ ហើយនិយោជកក៏បានរើអីវ៉ាន់ចេញពីរោងចក្រអស់ហើយដែរ។
    - ០ ចាប់តាំងពីថ្ងៃបញ្ឈប់កម្មករនិយោជិត មិនមានកម្មករនិយោជិតណាម្នាក់ធ្វើការតវ៉ាចំពោះការទូទាត់ប្រាក់បំណាច់ដែលនិយោជកទូទាត់ជូននោះទេ។
    - ០ ចំពោះការទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាជូនកម្មករនិយោជិត គឺនិយោជកអនុវត្តតាមលិខិតបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
    - ០ និយោជកគិតអតីតភាពការងាររបស់កម្មករនិយោជិតចាប់ពីពេលដែលប្តូរប្រភេទកិច្ចសន្យាការងាររបស់កម្មករនិយោជិត ពីកិច្ចសន្យាការងារមានថិរវេលាកំណត់ ទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ នៅចុងឆ្នាំ២០១៩ ដែលការអនុវត្តនេះ គឺយោងតាមលិខិតលេខ ០៧០ កប/អក/អធក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ របស់លោក អ៊ិក ចាន់ធូ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ។
- យោងតាមបញ្ជីឈ្មោះបញ្ជាក់ពីកម្មករនិយោជិតដែលទាមទារចំណុចនេះដាក់ជូនក្រុមអាជ្ញាកណ្តាលក្រោយថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញ ៖
    - ០ កម្មករនិយោជិតដែលទាមទារមានចំនួន ៣៣០នាក់ ដែលក្នុងចំណោមនេះ មានកម្មករនិយោជិតចំនួន ២នាក់ មានឈ្មោះ សំ រិត អត្តលេខ ១០៥៤៦ ចូលធ្វើការដំបូងថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៣ ដែលត្រូវបាននិយោជកបញ្ឈប់នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ និង [illegible] គង់ ស្រីពេជ្រ អត្តលេខ ៩៥៩៨ ចូលធ្វើការដំបូងថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣ ដែលត្រូវបាននិយោជកបញ្ឈប់នៅថ្ងៃ ទី២៨ ខែធ្នូ ឆ្នាំ២០២០។/

THE ARBITRATION COUNCIL

- ចំពោះកម្មករនិយោជិតចំនួន ២៩៤នាក់ទៀត ត្រូវបាននិយោជកបញ្ឈប់ក្រោយថ្ងៃទី១៥ ខែមករា ឆ្នាំ ២០២១ ជាបន្តបន្ទាប់ រហូតដល់ថ្ងៃបិទរោងចក្រ។
- រីឯកម្មករនិយោជិតចំនួន ៣០នាក់ទៀត មិនមានព័ត៌មានអំពីថ្ងៃចូលធ្វើការ និងថ្ងៃនិយោជក បញ្ឈប់ ហើយនិងកម្មករនិយោជិតចំនួន ២នាក់ មិនមានព័ត៌មានអំពីថ្ងៃចូលធ្វើការ និងកម្មករ និយោជិតចំនួន ២នាក់ មិនមានព័ត៌មានអំពីថ្ងៃនិយោជកបញ្ឈប់។
- តាមរយៈការរកឃើញខាងលើ ក្រុមអាជ្ញាកណ្តាលយល់ឃើញថា មានតែកម្មករនិយោជិតចំនួន ២នាក់ប៉ុណ្ណោះ មានឈ្មោះ សំ រិត និងឈ្មោះ គង់ ស្រីពេជ្រ ដែលមានអង្គហេតុ និងព័ត៌មាន នៃការបញ្ឈប់មុនថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ ដែលជាថ្ងៃកម្មករនិយោជិតបានដាក់ពាក្យ បណ្តឹង។ ហេតុដូចនេះ ក្រុមអាជ្ញាកណ្តាលពិចារណាការទាមទារចំណុចនេះ សម្រាប់កម្មករ និយោជិតដែលជាដើមបណ្តឹងចំនួន ២នាក់ តែប៉ុណ្ណោះ ដែលឈ្មោះ សំ រិត និងឈ្មោះ គង់ ស្រី ពេជ្រ។

## ហេតុផលនៃសេចក្តីសម្រេច ៖

**ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកគិតអតីតភាពការងាររបស់កម្មករនិយោជិតម្នាក់ៗ ដោយគិតចាប់ពីកិច្ចសន្យាការងារដំបូង រហូតដល់ថ្ងៃនិយោជកបញ្ឈប់ពីការងារ សម្រាប់ ទូទាត់ប្រាក់បំណាច់ជួសការជូនដំណឹងមុន ប្រាក់បំណាច់អតីតភាពការងារ និងសោហ៊ុយ ជំងឺចិត្ត ជូនកម្មករនិយោជិត**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចគិតអតីតភាពការងាររបស់កម្មករ និយោជិតម្នាក់ៗ ដោយគិតចាប់ពីថ្ងៃចូលធ្វើការដំបូង រហូតដល់ថ្ងៃនិយោជកបញ្ឈប់ពីការងារ សម្រាប់ទូទាត់ ប្រាក់ជួសការជូនដំណឹងមុន ប្រាក់បំណាច់អតីតភាពការងារ និងសោហ៊ុយជំងឺចិត្ត ជូនកម្មករនិយោជិត ដែរ ឬទេ?

យោងតាមកថាខណ្ឌទី៦ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"នៅពេលបញ្ចប់កិច្ចសន្យា និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតនូវប្រាក់បំណាច់បញ្ចប់កិច្ចសន្យានោះ ដែលសមាមាត្រនឹងប្រាក់ឈ្នួលផង សមាមាត្រនឹងថិរវេលានៃកិច្ចសន្យាការងារផង ហើយដែលចំនួនប្រាក់បំណាច់នេះ មានកំណត់ក្នុងអនុសញ្ញា រួម។ បើគ្មានកំណត់ក្នុងអនុសញ្ញារួមទេ ប្រាក់បំណាច់នេះយ៉ាងតិចត្រូវស្មើប្រាំភាគរយនៃប្រាក់ឈ្នួល ដែលកម្មករ និយោជិតបានបើកនៅក្នុងរយៈពេលនៃកិច្ចសន្យា។*

កថាខណ្ឌទី៧ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារដដែល ចែងថា ៖ *"ប្រសិនបើកិច្ចសន្យាដែលគ្មានកំណត់ ថិរវេលាពិតប្រាកដ មកជំនួសកិច្ចសន្យាដែលមានកំណត់ថិរវេលាពិតប្រាកដនៅពេលចប់កិច្ចសន្យា អតីតភាព ការងារនៃកម្មករនិយោជិត ត្រូវបានគិតដោយយកថិរវេលានៃកិច្ចសន្យាទាំងពីរមកបូកបញ្ចូលគ្នា។"*

យោងតាមកថាខណ្ឌទី ៦ និង៧ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញ ថា បើទោះបីជានិយោជកបានទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំនួន ៥ភាគរយ ហើយក៏ដោយ ក៏ការទូទាត់ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ នៅពេលភាគីកំពុងអនុវត្តកិច្ចសន្យា មិនមែនជាការបញ្ចប់កិច្ចសន្យា ការងារនោះទេ ព្រោះករណីនេះ និយោជកនៅតែបន្តចុះកិច្ចសន្យាការងារជាមួយកម្មករនិយោជិតជាបន្តបន្ទាប់ ដោយនៅតែបន្តការងារជាធម្មតា។ លើសពីនេះទៀត នៅពេលដែលកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា

បានប្រែក្លាយទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ នោះអតីតភាពការងាររបស់កម្មករនិយោជិត គឺត្រូវគិតដោយយកថិរវេលានៃកិច្ចសន្យាការងារទាំងពីរ មកបូកបញ្ចូលគ្នា ពោលគឺគិតចាប់ពីកិច្ចសន្យាការងារដំបូងមក។

យោងតាមអង្គហេតុ នៅចុងឆ្នាំ២០១៩ និយោជកបានផ្លាស់ប្តូរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ដែលមានថិរវេលាកំណត់ ទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់វិញ និងបានទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារដែលមានថិរវេលាកំណត់ចំនួន ៥ភាគរយ ជូនកម្មករនិយោជិតរួចហើយមុនពេលផ្លាស់ប្តូរប្រភេទនៃកិច្ចសន្យា។ ភាគីកម្មករនិយោជិតបានអះអាងថា និយោជកមិនបានគិតអតីតភាពការងាររបស់កម្មករនិយោជិតសម្រាប់ទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារ ចាប់ពីថ្ងៃដែលបានចុះកិច្ចសន្យាការងារដំបូង រហូតដល់ថ្ងៃនិយោជកបញ្ឈប់កម្មករនិយោជិតនោះទេ។ បន្ថែមពីនេះ កម្មករនិយោជិតបានអះអាងនៅក្នុងសារណាបញ្ជាក់ត្រង់ចំណុចទី១ថា ការអនុវត្តគិតអតីតភាពការងាររបស់និយោជក គឺផ្ទុយពីខ្លឹមសារកថាខណ្ឌទី៧ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារ។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា ការគិតអតីតភាពការងារកម្មករនិយោជិតសម្រាប់ទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យា គឺផ្អែកលើកិច្ចសន្យាការងាររបស់កម្មករនិយោជិតដែលបានប្តូរទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់នៅចុងឆ្នាំ២០១៩ លិខិតបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងលិខិតលេខ ០៧០ កប/អក/អធក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ របស់ប្រធាននាយកដ្ឋានអធិការកិច្ចការងារ។

នៅខែកក្កដា ឆ្នាំ២០១៩ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ បានចេញសេចក្តីជូនដំណឹងលេខ ០២៣/១៩ ក.ប/សជណខល ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ និងការទូទាត់ប្រាក់បំណាច់អតីតភាពការងារថ្មី ចាប់ពីឆ្នាំ២០១៩ តទៅ សម្រាប់សហគ្រាសគ្រឹះស្ថាន វាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង។

យោងតាមសេចក្តីជូនដំណឹងលេខ ០២៣/១៩ ក.ប/សជណខល នេះ នៅក្នុងចំណុចទី៤ បានបញ្ជាក់ថា *"ក្នុងករណីនិយោជកបាននឹងកំពុងប្រើប្រាស់កិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) លើសថិរវេលាអតិបរមាកំណត់ដោយច្បាប់ កិច្ចសន្យាការងារមានកំណត់ថិរវេលា(FDC)នោះ ត្រូវប្រែក្លាយទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) យ៉ាងយូរ ត្រឹមដំណាច់ឆ្នាំ២០១៩ ដោយនិយោជកត្រូវទូទាត់ប្រាក់បំណាច់អតីតភាពការងារ ចាប់ពីកាលបរិច្ឆេទប្រែក្លាយនោះ ស្របតាមមាត្រា ៨៩ថ្មី នៃច្បាប់ស្តីពីការងារ, ប្រកាសលេខ ៤៤៣ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ និងសេចក្តីណែនាំពាក់ព័ន្ធជាធរមាន។"*

ផ្អែកលើអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីណែនាំលេខ ០២៣/១៩ នេះ នៅតែបើកឱ្យមានការបកស្រាយខុសគ្នាដដែល ព្រោះសេចក្តីជូនដំណឹងនេះ មិនបានចែងឱ្យបានច្បាស់លាស់អំពីការគិតអតីតភាពការងាររបស់កម្មករនិយោជិត សម្រាប់ទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាពេលនិយោជកផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតនោះទេ។

បន្ថែមពីនេះទៀត ដោយយោងតាមសេចក្តីជូនដំណឹងលេខ ០២៣/១៩ ក.ប/សជណខល ខាងលើ នាយកដ្ឋានអធិការកិច្ចការងារ បានចេញលិខិតលេខ ០៧០ កប/អក/អធក នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានកម្មវត្ថុ ៖ របៀបគិតអតីតភាពការងារ ដើម្បីកំណត់រយៈពេលជូនដំណឹងមុន ដែលនិយោជកត្រូវអនុវត្ត

ពេលបញ្ចប់កិច្ចសន្យាការងារ ក្នុងករណីដែលកិច្ចសន្យាការងារមានកំណត់ថិរវេលា(FDC)ក្លាយទៅជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់(UDC)។

ភាគីកម្មករនិយោជិតយល់ឃើញថា លិខិតលេខ ០៧០ កប/អក/អធក ធ្វើឱ្យខូចប្រយោជន៍ដល់កម្មករនិយោជិតដែលកំណត់ដោយច្បាប់។ ចំណែកឯភាគីនិយោជកយល់ឃើញថា និយោជកបានអនុវត្តបានត្រឹមត្រូវតាមលិខិតលេខ ០៧០ កប/អក/អធក ហើយ ដោយគិតអតីតភាពចាប់ពីខែមករា ឆ្នាំ២០១៩ រហូតដល់ថ្ងៃបញ្ចប់កិច្ចសន្យាការងារ ព្រោះលិខិតនេះបានកំណត់ថា *"..ដើម្បីអនុវត្តកាតព្វកិច្ចជូនដំណឹងមុន ក្នុងករណីបញ្ចប់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ដែលប្រែក្លាយមកពីកិច្ចសន្យាការងារមានកំណត់ថិរវេលា និយោជកត្រូវគណនាអតីតភាពការងារសម្រាប់ការជូនដំណឹងមុន ដោយគិតចាប់ពីពេលដែលកិច្ចសន្យានេះ ត្រូវបានប្រែក្លាយជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ប្រសិនបើនិយោជកបានទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារមានថិរវេលាកំណត់ម្ដងរួចហើយ។...។"*

ទាក់ទងនឹងការលើកឡើងរបស់ភាគីកម្មកនិយោជិត និងនិយោជក អំពីខ្លឹមសារនៃលិខិតលេខ ០៧០ កប/អក/អធក ដែលផ្ទុយនឹងខ្លឹមសារមាត្រា ៧៣ កថាខណ្ឌទី ៧ នៃច្បាប់ស្ដីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ករណីនេះ គឺជាទំនាស់នៃច្បាប់ ដែលមិនមែនជាយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនោះទេ។

មាត្រា ៤៧ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ បានចែងថា ៖ *"រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាស សេចក្ដីសម្រេច សារាចរ និងសេចក្ដីណែនាំ។*

*ប្រកាស សេចក្ដីសម្រេច សារាចរ ឬសេចក្ដីណែនាំរបស់ក្រសួង មិនអាចចែងអំពីកិច្ចការដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងនោះ ហើយក៏ពុំអាចមានទំនាស់ជាមួយលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលឡើយ។"*

យោងតាមមាត្រា ៤៧ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្ដាលយល់ឃើញថា រដ្ឋមន្ត្រីមានសិទ្ធិក្នុងការចេញប្រកាស សេចក្ដីសម្រេច សារាចរ និងសេចក្ដីណែនាំផ្សេងៗ អំពីកិច្ចការដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រសួងនោះ ប៉ុន្តែរាល់ការចេញប្រកាស សារាចរ សេចក្ដីសម្រេច ឬសេចក្ដីណែនាំនោះ មិនត្រូវផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តនានានោះទេ។

ហេតុនេះ យោងតាមសេចក្ដីជូនដំណឹងលេខ ០២៣/១៩ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជា-ជីវៈ ភាគីនិយោជក និងកម្មករនិយោជិត មានកាតព្វកិច្ចក្នុងការអនុវត្តតាមសេចក្ដីជូនដំណឹងនោះ។

ប៉ុន្តែ ប្រសិនបើភាគីណាមួយ ឬភាគីទាំងពីរយល់ឃើញថា សេចក្ដីជូនដំណឹងលេខ ០២៣/១៩ ក.ប/សជណខល នេះ ផ្ទុយនឹងច្បាប់ស្ដីពីការងារ ហើយបានធ្វើឱ្យខូចខាតប្រយោជន៍ ឬប៉ះពាល់ដល់សិទ្ធិរបស់ខ្លួន ឬលិខិតលេខ ០៧០ កប/អកធក ដែលចេញដោយនាយកដ្ឋានអធិការកិច្ចការងារ ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍តាមច្បាប់កំណត់ ភាគីណាមួយ ឬភាគីទាំងពីរគួរតែស្នើសុំការបកស្រាយពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដែលមានអំណាចបកស្រាយអំពីវិវាទគតិយុត្ត ឬតុលាការមានសមត្ថកិច្ច ឬក្រុមប្រឹក្សាធម្មនុញ្ញ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ទាក់ទងនឹងការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកគិតអតីតភាពការងារ ចាប់ពីថ្ងៃចុះកិច្ចសន្យាការងារដំបូង រហូតដល់ថ្ងៃបញ្ចប់កិច្ចសន្យាការងារ ដើម្បីទូទាត់ប្រាក់បំណាច់ជួសការជូនដំណឹង ប្រាក់បំណាច់អតីតភាពការងារ និងប្រាក់សោហ៊ុយជំងឺចិត្ត ជូនកម្មករនិយោជិតម្នាក់ៗ នៅក្នុងសំណុំរឿងនេះ គឺជាចំណោទផ្លូវច្បាប់មួយថា តើត្រូវយកច្បាប់ស្ដីពីការងារ ឬយកសេចក្ដីជូនដំណឹងលេខ ០២៣/១៩ មកអនុវត្តចំពោះករណីនេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនមានអំណាចសម្រេចលើ

ខ្លឹមសារនៃសេចក្តីជូនដំណឹងលេខ ០២៣/១៩ ឬលិខិតលេខ ០៧០ កប/អកធក ថា ផ្ទុយពីច្បាប់ស្តីពីការងារ ហើយធ្វើឱ្យខូចខាតប្រយោជន៍ ឬប៉ះពាល់ដល់សិទ្ធិរបស់ភាគីនោះទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទារ របស់ភាគីកម្មករនិយោជិត ឱ្យនិយោជកគិតអតីតភាពការងាររបស់កម្មករនិយោជិតម្នាក់ៗ ដោយគិតចាប់ពីកិច្ចសន្យាការងារដំបូង រហូតដល់ថ្ងៃនិយោជកបញ្ឈប់ពីការងារ សម្រាប់ទូទាត់ប្រាក់បំណាច់ជួសការជូនដំណឹងមុន ប្រាក់បំណាច់អតីតភាពការងារ និងសោហ៊ុយជំងឺចិត្ត។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកគិតអតីតភាពការងាររបស់កម្មករនិយោជិតម្នាក់ៗ ដោយគិតចាប់តាំងពីកិច្ចសន្យាការងារដំបូង រហូតដល់ថ្ងៃនិយោជកបញ្ឈប់ពីការងារ សម្រាប់ទូទាត់ប្រាក់បំណាច់ជួសការជូនដំណឹងមុន ប្រាក់បំណាច់អតីតភាពការងារ និងសោហ៊ុយជំងឺចិត្ត។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------

**ឧបសម្ព័ន្ធនៃសេចក្តីបង្គាប់លេខ ០០៨/២១-វ៉ៃ ហ៊្វីល ហ្គាមេន (ខេមបូឌា)**

# យោបល់ជំទាស់ទៅលើសេចក្តីសម្រេច
# នៃសំណុំរឿងលេខ ០០៨/២១-វ៉ៃ ហ៊្វីល ហ្គាមេន (ខេមបូឌា)

## ដោយអាជ្ញាកណ្តាល អាន វីរៈ ដែលជ្រើសរើសដោយភាគីសហជីពកម្មករនិយោជិត

ប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានចែងថា *"ក្រុមអាជ្ញាកណ្តាលត្រូវកត់ត្រារាល់សេចក្តីសម្រេចរបស់ខ្លួនក្នុងសេចក្តីបង្គាប់មួយ ដែលត្រូវចុះហត្ថលេខារបស់អាជ្ញាកណ្តាលទាំង ០៣ រូប។* ***ក្នុងករណីដែលអាជ្ញាកណ្តាលណាម្នាក់មិនឯកភាពនឹងសេចក្តីសម្រេចតាមមតិភាគច្រើននោះ គាត់អាចកត់ត្រាយោបល់ជំទាស់របស់គាត់ធ្វើជាឧបសម្ព័ន្ធមួយក្នុងសេចក្តីបង្គាប់នោះ"***។

យោងតាមប្រការនេះ ខ្ញុំអាជ្ញាកណ្តាល **អាន វីរៈ** សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងហេតុផល នៃសេចក្តីសម្រេចក្នុងសេចក្តីបង្គាប់លេខ **០០៨/២១-វ៉ៃ ហ៊្វីល ហ្គាមេន** ដែលបដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត។

ក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតស្នើសុំឱ្យរោងចក្រ រាល់ពេលបញ្ឈប់កម្មករនិយោជិតពីការងារ ទូទាត់អតីតភាពការងារតាមច្បាប់ស្តីពីការងារ។ ខ្ញុំយល់ឃើញថា ក្នុងសំណុំរឿងនេះ កម្មករនិយោជិតមិនបានធ្វើការទាមទារឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការបកស្រាយបទបញ្ញត្តិច្បាប់ជាក់លាក់ណាមួយនោះទេ ទោះបីជាមានការលើកឡើងផ្សេងគ្នា រវាងភាគីទាំងពីរនៃវិវាទក្នុងសវនការ ទាក់ទងនឹងបទបញ្ញត្តិពាក់ព័ន្ធផ្សេងគ្នាក៏ដោយ។

មាត្រា ៣១២ កថាខណ្ឌទី១-២ នៃច្បាប់ស្តីពីការងារចែងថា៖

ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុ ជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ។

ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទ ដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិច្បាប់ឬអនុសញ្ញារួមណាមួយ។ ក្រុមប្រឹក្សានេះដោះស្រាយដោយសមធម៌ចំពោះការវិវាទឯទៀតទាំងអស់។

ប្រការ ៣៤ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា៖

ចំពោះបញ្ហាដែលបានដាក់ជូនក្រុមអាជ្ញាកណ្តាល ក្រុមនេះមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីវិវាទផ្តល់សំណងយ៉ាងពេញលេញ ចំពោះរាល់ការបំពានបទបញ្ញត្តិដែលមានក្នុងច្បាប់ស្តីពីការងារ បទបញ្ញត្តិអនុវត្តច្បាប់ស្តីពីការងារ អនុសញ្ញារួម ឬកាតព្វកិច្ចផ្សេងទៀត ដែលកើតចេញពីទំនាក់ទំនងវិជ្ជាជីវៈ រវាងនិយោជក និងកម្មករនិយោជិត។ ...

យោងតាមមាត្រាច្បាប់ស្តីពីការងារ និងប្រការនៃប្រកាសខាងលើ ខ្ញុំយល់ឃើញថា ក្រុមអាជ្ញាកណ្តាលទទួលបានអំណាចពេញលេញ ក្នុងការសម្រេចដោះស្រាយពិចារណាចំណុចវិវាទដែលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយផ្អែកលើច្បាប់ស្តីពីការងារ និងប្រកាសអនុវត្តច្បាប់ស្តីពីការងារនានា ដែលទាក់ទងនឹងចំណុចវិវាទដែលបានបញ្ជូនមក។

ក្នុងសំណុំរឿងនេះ ចំណុចវិវាទបានបញ្ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យដោះស្រាយ គឺទាក់ទងនឹងការគិតអតីតភាពការងារនៅពេលការបញ្ចប់កិច្ចសន្យាការងារតាមច្បាប់ស្តីពីការងារ ខ្ញុំយល់ឃើញថា ចំណុចវិវាទនេះ ស្ថិតក្នុងអំណាចដែលច្បាប់ស្តីពីការងារបានប្រគល់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយ។ ម្យ៉ាងវិញ ខ្ញុំយល់ឃើញថា ក្រុមអាជ្ញាកណ្តាលមានអំណាចក្នុងសម្រេចយកមាត្រាច្បាប់ស្តីពីការងារ ប្រកាស និងបទដ្ឋានគតិយុត្តិដែលត្រូវអនុវត្តចំពោះចំណុចវិវាទនេះ។ លើសពីនេះ ចំណុចវិវាទរបស់ភាគីកម្មករនិយោជិត មិនបានទាមទារឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការសម្រេចបកស្រាយលិខិតបទដ្ឋានណាមួយ ដែលពាក់ព័ន្ធនឹងការបញ្ចប់កិច្ចសន្យាការងារនោះទេ វាជាអំណាចរបស់ក្រុមអាជ្ញាកណ្តាលក្នុងការបកស្រាយ និងសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងបទបញ្ញត្តិដែលត្រូវអនុវត្តចំពោះចំណុចវិវាទនេះ។

ហេតុនេះ ខ្ញុំយល់ថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលគប្បីពិចារណាលើចំណុចវិវាទដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនគួរបដិសេធពិចារណានោះទេ។

ថ្ងៃពុធ ១៤កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១
ហត្ថលេខាអាជ្ញាកណ្តាល

**អាន វីរៈ**